មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ សុខ គឿន ភេទស្រី អាយុ៥៤ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ "ពេទ្យ"**

**ស្រុកកំណើតនៅភូមិសង្គមថ្មី ឃុំស្ដៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ**

**រស់នៅភូមិបន្ទាយចាស់ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សុខ វណ្ណៈ**

**០១:០១:៣៨**

**៣០ទំព័រ**

វណ្ណៈ: ចឹងកុំឲ្យយូរខ្ញុំប្រាប់មីងថា ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំបានមកដល់ភូមិឃុំមីង គឺចង់ដឹងរឿងរ៉ាវដែលបានកើតឡើងប៉ុន្មានជំនាន់កាលហ្នឹង មីងបានឆ្លងកាត់ប៉ុន្មានជំនាន់ហ្នឹងមីងណាស់ ហើយរឿងរ៉ាវទាំងអស់ហ្នឹងខាងខ្ញុំហ្នឹង យកទៅសរសេរជាសៀវភៅមួយដើម្បីឲ្យក្មេងៗបានសិក្សារៀនសូត្រ ឲ្យដឹងពីការរស់នៅរបស់ឪពុកម្ដាយឬចាស់ទុំជំនាន់មុនគាត់បានឆ្លងកាត់អីខ្លះ? ចឹងបទសម្ភាសខ្ញុំជាមីង ចង់យកទៅទុកជាឯកសារ ចឹងខ្ញុំអាចសម្ភាសមីងហើយយកទៅសរសេរជាសៀវភៅមីងមិនថាអីទេ?

គឿនៈ ចាស!មានថាអី ។

វណ្ណៈ: ចឹងថ្ងៃហ្នឹងថ្ងៃទី២១ខែ១២ឆ្នាំ២០១៣ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរមីង?

គឿនៈ ឈ្មោះ សុខ គឿន ។

វណ្ណៈ: មីងអាយុប៉ុន្មានហើយពល់ថ្ងៃ?

គឿនៈ អាយុ១៩៥៩អះ៦៩ ។

វណ្ណៈ: ១៩៦៩?

គឿនៈ ចាស ។

វណ្ណៈ: ប្ដីមីងឈ្មោះអីដែរ?

គឿនៈ ចាន ពឿន ។

វណ្ណៈ: គាត់អាយុប៉ុន្មានដែរ?

គឿនៈ អាយុ៧៧ ។

វណ្ណៈ: ចឹងពល់ថ្ងៃមីងប្រកបមុខរបរអីដែរ?

គឿនៈ មានធ្វើអីទេ ចិញ្ចឹមជ្រូក ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំ និងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

វណ្ណៈ ចឹងចឹញ្ចឹមជ្រូកធ្វើស្រែដែរ?
គឿនៈ ចាស!ធ្វើស្រែ ។
វណ្ណៈ ចឹងពូគាត់ធ្វើការអីដែរ?
គឿនៈ គាត់ជំទប់ទី១ឃុំ ។
វណ្ណៈ មីងមានកូនចៅប៉ុន្មាននាក់រាល់ថ្ងៃ?
គឿនៈ មានកូន៤ ។
វណ្ណៈ ស្រីប៉ុន្មាន?
គឿនៈ ប្រុសទាំងអស់ ។
វណ្ណៈ ចឹងកូនទាំង៤ហ្នឹងបានរៀបការខ្លះឬនៅឬមួយនៅក្នុងបន្ទុកមីងដដែល?
គឿនៈ រៀបការពីរហើយ ។
វណ្ណៈ ចឹងពីរហ្នឹងនៅផ្ទះផ្សេងហើយ?
គឿនៈ ផ្ទះផ្សេងហើយ ។
វណ្ណៈ ចឹងនៅពីរទៀតសុទ្ធតែកូនប្រុសចឹងឲ្យលុយគេរហូត?
គឿនៈ ឲ្យលុយរហូត ។
វណ្ណៈ ចឹងភូមិកំណើតមីងនៅណាដែរ?
គឿនៈ នៅព្រះវិហារ ។
វណ្ណៈ ចឹងភូមិ?
គឿនៈ ភូមិសង្គមថ្មី ឃុំស្ដៅ ។
វណ្ណៈ ស្រុក?
គឿនៈ ស្រុកសង្គមថ្មីដែរ ខេត្តព្រះវិហារ ។
វណ្ណៈ ចឹងឥឡូវមីងនៅភូមិអីដែរ?
គឿនៈ នៅបន្ទាយចាស់ ។
វណ្ណៈ ឃុំ?
គឿនៈ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។
វណ្ណៈ ចឹងយ៉ាងម៉េចបានគេដាក់ភូមិបន្ទាយចាស់ចឹងមីងមានដឹងទេ?
គឿនៈ អត់ដឹងទេ ។
វណ្ណៈ ចឹងភូមិបន្ទាយចាស់ហ្នឹង កាលសម័យតាម៉ុក គ្រប់គ្រងគេហៅភូមិលេខប៉ុន្មាន អង្គភាពលេខប៉ុន្មានដែរ?

គឿន៖ ខ្ញុំអត់ដឹងទេ ។

វណ្ណៈ កងពល?

គឿន៖ ចាស! អត់ដឹង ខ្ញុំមិនសូវដឹងទេ ។

វណ្ណៈ មិនមែននៅកងពលតាហឿន ទេ?

គឿន៖ នៅកងពលតាហឿន តែមិនថាលេខប៉ុន្មានទេ ។

វណ្ណៈ កងពលតាហឿន កងពល៦១២?

គឿន៖ ចាស! ប្រហែលចឹងហើយ ។

វណ្ណៈ ឪពុកមីងឈ្មោះអីដែរ?

គឿន៖ ឪពុកខ្ញុំឈ្មោះ មាស គីម គាត់ស្លាប់យូរណាស់ហើយ ។

វណ្ណៈ ម្ដាយ?

គឿន៖ ម្ដាយឈ្មោះ សុខ ហែម ។

វណ្ណៈ គាត់នៅរស់ដែរ?

គឿន៖ អត់ ។

វណ្ណៈ ស្លាប់ដែរ?

គឿន៖ ចាស ។

វណ្ណៈ បងប្អូនមីងទាំងអស់មានប៉ុន្មាននាក់?

គឿន៖ បងប្អូនខ្ញុំមានបីនាក់ ។

វណ្ណៈ ចឹងតិចដែរ?

គឿន៖ ចាស ។

វណ្ណៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

គឿន៖ ស្រី២ប្រុស១ ។

វណ្ណៈ ចឹងបងទី១ឈ្មោះអី?

គឿន៖ ឈ្មោះស្អីទេ ឈ្មោះ ចាន់ គួន ។

វណ្ណៈ ចឹងទី២?

គឿន៖ ទី២ខ្ញុំ ។

វណ្ណៈ ទី៣?

គឿន៖ សុខ គា ។

វណ្ណៈ ចឹងបងប្អូនមីងរាល់ថ្ងៃនៅរស់ទាំងអស់ទេ?

គឿន៖	នៅរស់ទាំងអស់ ។

វណ្ណៈ	ចឹងរាល់ថ្ងៃនៅស្រុកកំណើតឬក៏?

គឿន៖	នៅស្រុកកំណើត ។

វណ្ណៈ	ចឹងនៅនេះតែមីងមួយទេ?

គឿន៖	ចាស ។

វណ្ណៈ	ចឹងកាលពីតូចមីងមានបានរៀនសូត្រទេ?

គឿន៖	ខ្ញុំបានរៀនបន្តិចដែលហ្នឹង ។

វណ្ណៈ	រៀនត្រឹមថ្នាក់ទីប៉ុន្មាន?

គឿន៖	រៀនត្រឹមថ្នាក់ទី១១ រដ្ឋប្រហារ គ្រូមកពីឆ្ងាយណា លោកគ្រូ ន័យ ប៉េណា គាត់នៅខេត្ត ស្វាយរៀននោះ សព្វថ្ងៃដឹងគាត់ធ្វើអី គាត់ឯកឧត្តមក្ដដឹងឃើញក្នុងសៀវភៅ ។

វណ្ណៈ	គាត់ឈ្មោះ អីគេ?

គឿន៖	ន័យ ប៉េណា ។

វណ្ណៈ	ចឹងគាត់មកបង្រៀនដល់ខេត្តហ្នឹង?

គឿន៖	គាត់មកបង្រៀននៅខេត្តព្រះវិហារសុទ្ធតែគ្រូមកពីក្រោមទាំងអស់ មកបង្រៀនហ្នឹងតែរៀន វាមិនយូរស្រុកមានសង្គ្រាមនោះ ។

វណ្ណៈ	សម័យសង្គមរាស្ត្រនិយមពីដើមហ្នឹង?

គឿន៖	ចាស!ឆ្នាំ១៩៦០ខ្ញុំនៅតូចមិនមើលប្រវត្តិហ្នឹង អាយុហ្នឹងសន្និប៉ុណ្ណឹងឯង ។

វណ្ណៈ	កាលហ្នឹងរៀននៅសាលាបឋមសិក្សាឈ្មោះអីដែលគេ?

គឿន៖	នៅស្រុកសង្គមថ្មីហ្នឹងឯង ភូមិបឹង សាលាហ្នឹង តែសាលាឈើទេ អត់មានសាលាថ្មចឹងទេ ពីសង្គម ជំនាន់ហ្នឹងមិនទាន់មានថ្មទេ ។

វណ្ណៈ	ចឹងមីងឈប់រៀននៅពេលណា?

គឿន៖	ខ្ញុំឈប់រៀននៅឆ្នាំ១៩៧២ ។

វណ្ណៈ	ចឹងពេលរដ្ឋប្រហារហើយនៅបានរៀនទៀតចឹង?

គឿន៖	បាទរៀន តែលោកគ្រូ កាលរដ្ឋប្រហារឆ្នាំ៧០នោះរត់ចុះរត់ឡើង រៀនបានមួយៗចឹងខាន ១០ថ្ងៃចុះលោកគ្រូខ្លាចនោះ គេរកចាប់មួយសារនោះគ្រូ គ្រូៗរត់ទៅមកៗ គាត់គេច ។

វណ្ណៈ	ចឹងកាលហ្នឹងឆ្នាំ១៩៧១-៧២ មានទម្លាក់គ្រាប់បែកហើយយ៉ាងម៉េចបានរៀនទៀត?

គឿន៖	ចាស!មិនបានទេ ឈប់បានរៀនហើយ ឆ្នាំ៧១បានរៀនបន្តិចដែរ ៧២ចប់ហើយ ខ្ញុំបាន ថ្នាក់ទី១១ហ្នឹងចុងៗទេ តែមើលបានឈ្មោះ ខ្លួនឯងអីនោះខ្ញុំ ។

វណ្ណៈ	ចឹងកាលហ្នឹងមានទម្លាក់គ្រាប់បែកទេ?
គៀនៈ	មាន យន្តហោះគេហៅអាមិចៗ នោះហោះយប់ក៏មានកាលនោះ ។
វណ្ណៈ	មានគ្រោះថ្នាក់ទេ?
គៀនៈ	អត់មានទេ ។
វណ្ណៈ	ចឹងពេលឈប់រៀនហើយ មីងមកជួយធ្វើស្រែឪពុកម្តាយឬមីងចូលចលនាបដិវត្តកាលហ្នឹងមីង?
គៀនៈ	អត់ទេ នៅធ្វើស្រែជាមួយឪពុកម្តាយ ។
វណ្ណៈ	ចឹងក្រោយមកទៀត?
គៀនៈ	ក្រោយមកទៀតឆ្នាំ៧៤បានខ្ញុំចូលបដិវត្ត ។
វណ្ណៈ	កាលហ្នឹងមីងស្ម័គ្រចិត្តទៅដែលឬមួយយ៉ាងម៉េច?
គៀនៈ	ស្ម័គ្រចិត្តផងគេរើសផង ឆ្នាំ៧០នៅតូច៧១-៧២នៅតូចដែរ ដល់ឆ្នាំ៧៤បានគេស្នើទៅកាលហ្នឹង ។
វណ្ណៈ	អាយុប្រហែលជាប៉ុន្មានដល់ឆ្នាំ៧៤?
គៀនៈ	៧៤ពូគិតមើលអាចអាយុ១៥អីដែរ ។
វណ្ណៈ	ចឹងកាលហ្នឹងចូលដំបូង មីងចូលទៅធ្វើអីដែរ ទៅកន្លែងណាខាងសិល្បៈឬធ្វើអីគេ?
គៀនៈ	ចូលទៅកងចល័តធ្វើស្រែចម្ការដែលហ្នឹងកងចល័តហ្នឹង ។
វណ្ណៈ	កងចល័តស្រុកឬមួយយ៉ាងម៉េច?
គៀនៈ	កងចល័តស្រុក ។
វណ្ណៈ	ចឹងបន្ទាប់ទៀតឆ្នាំ៧៤ដល់៧៥មីងធ្វើអីទៀត?
គៀនៈ	ឆ្នាំ១៩៧៥ខ្ញុំបានចូលដល់ភ្នំពេញ នៅក្រុងភ្នំពេញ ។
វណ្ណៈ	ចឹងមីងកាលហ្នឹងមានបានកាន់កាំភ្លើងឡើងវាយទេ?
គៀនៈ	អត់មានទេ ។
វណ្ណៈ	គេយកឡានមកដឹកទៅភ្នំពេញ?
គៀនៈ	ទៅភ្នំពេញ ពួកខ្ញុំពេទ្យទេ គេហៅពេទ្យ១៧មេសា ឥឡូវនេះគេហៅពេទ្យរុស្សី ខ្ញុំធ្វើពេទ្យមិនមានកាំភ្លើងកាន់អីហ្នឹងគេទេ ។
វណ្ណៈ	ចឹងពេលមីងបានទៅដល់ភ្នំពេញមីងបានទៅធ្វើពេទ្យតែម្តង?
គៀនៈ	ចាស!ចូលពេទ្យតែម្តង ពេទ្យតាំងពីនៅសង្គ្រាមឆ្នាំ៧៤ម្លេះ ។
វណ្ណៈ	ចឹងមីងថាកងចល័តស្រុក?

គឿន៖ កងចល័តហ្នឹងបានតែ៧ខែទេ ទៅដល់ពេលពេទ្យបណ្ដោយចូល៧៥ហ្នឹង ធ្វើពេទ្យរហូតមកដល់៧៩វត់ ។

វណ្ណៈ៖ ចឹងពេលបែកភ្នំពេញមកធ្វើពេទ្យ១៧មេសា?

គឿន៖ ចាស ។

វណ្ណៈ៖ ឥឡូវហៅពេទ្យរុស្ស៊ី?

គឿន៖ ចាស!ហៅពេទ្យរុស្ស៊ី ។

វណ្ណៈ៖ ចឹងកាលហ្នឹងគេយកមកពីស្រុកគ្នាច្រើនទេ ដែលគេដឹកយកមកធ្វើពេទ្យហ្នឹង?

គឿន៖ អត់មានទេ ពួកខ្ញុំទៅពីនេះអត់មានទេ ទៅស្គាល់គ្នាទៅ ។

វណ្ណៈ៖ គេមកយកមីងដឹកឡានទៅឬមួយយ៉ាងម៉េច?

គឿន៖ អត់មានមកយកទេ ទៅខ្លួនឯងទៅដូចថាយើងចូលអង្គភាពណា មេអង្គភាពហ្នឹងតម្រូវថាអង្គភាពនេះទៅប៉ុន្មាននាក់ គេត្រូវយកម្នាក់ឬពីរនាក់ចឹង អង្គភាពមួយមនុស្សមួយឬពីរចឹងទៅ ។

វណ្ណៈ៖ ចឹងអង្គភាពមីងយកតែមីងទៅទេ?

គឿន៖ ចាស!យកតែខ្ញុំមួយទេ ។

វណ្ណៈ៖ ចឹងទៅជួបគ្នានៅណានៅខេត្តឬនៅណា?

គឿន៖ ទេ ស្ទឹងភូមិស្ទឹងហួសចម្ការលើទៀត ទៅហ្នឹងមិនធម្មតាទេ ។

វណ្ណៈ៖ ចឹងមីងនៅហ្នឹងគេជូនទៅឬយ៉ាងម៉េច?

គឿន៖ គេជូនទៅ ។

វណ្ណៈ៖ ចឹងមីងមិនអាចស្គាល់ភ្នំពេញបានទេ?

គឿន៖ ខ្ញុំមិនអាចស្គាល់ទេ ។

វណ្ណៈ៖ ចឹងមីងទៅដល់ភ្នំពេញឆ្នាំ៧៥ដែរ ប្រជាជនចេញអស់ពីទីក្រុងហើយពេលហ្នឹង?

គឿន៖ មាននៅមួយៗ ខ្ញុំនិយាយត្រង់ៗហើយខ្ញុំមិនចេះកុហក់ទេ តែចេញហ្នឹងមិនថាគេដេញយ៉ាងម៉េចអីយ៉ាងម៉េចទេ ទៅឃើញគេចេញនៅមួយៗទេ ចេញមិនទាន់អស់ទេ ។

វណ្ណៈ៖ ចឹងពេលហ្នឹងយើងជាអ្នកចលនាចឹងខ្លះគេឲ្យទៅបោសសម្អាតផ្ទះសំបែងឬគេឲ្យទៅធ្វើពេទ្យចឹង?

គឿន៖ ចាស ។

វណ្ណៈ៖ ចឹងមីងគេឲ្យចូលទៅក្នុងមន្ទីរពេទ្យ?

គឿន៖ ខ្ញុំចូលទៅក្នុងមន្ទីរពេទ្យតែម្ដង ។

វណ្ណៈ	ចឹងពេលមីងចូលទៅដល់ក្នុងមន្ទីរពេទ្យភ្លាមៗនៅក្នុងទីក្រុងភ្នំពេញហ្នឹង តើមីងមានបានឃើញមានអ្នកជំងឺជាប្រជាជនឬជាទាហានអីយ៉ាងម៉េចកាលហ្នឹង?

គឿនៈ	មាន ។

វណ្ណៈ	ចឹងមានប្រជាជននៅក្នុងពេទ្យហ្នឹងដែរ?

គឿនៈ	ខ្លះទៅមិនរួចឃើញនៅហ្នឹង ។

វណ្ណៈ	មានឃើញស្លាប់នៅហ្នឹងទេ?

គឿនៈ	មានស្លាប់រលួយ តែមិនមែននៅលើគ្រែទេ នៅលើឥដ្ឋការ៉ូក៏ឃើញដែរ ឃើញជាន់ទី៥ជាន់ទី៤ ។

វណ្ណៈ	ចឹងមីងជាស្ត្រីចឹង ហើយមីងបានឃើញទិដ្ឋភាពបែបហ្នឹង មីងមានការភ័យខ្លាចទេ?

គឿនៈ	ខ្លាច ។

វណ្ណៈ	ចឹងគេមានប្រើមីងឲ្យទៅលែងខ្មោចគេមានបទបញ្ជាដែរ?

គឿនៈ	គេអត់មានឲ្យទៅទេ កាលនោះខ្ញុំមិនដែលបានសែងខ្មោចណាទេ ។

វណ្ណៈ	ចឹងមីងឃើញ ចឹងគេឲ្យប្រុសៗសែងឬយ៉ាងម៉េច?

គឿនៈ	ចាស!ខ្ញុំកាលនោះនៅស្ទើរដែរ ។

វណ្ណៈ	ចឹងគេឲ្យប្រុសឬយ៉ាងម៉េច?

គឿនៈ	មិនដឹងជាប្រុសៗឬស្រីៗ ពួកខ្ញុំកូនក្មេងគេឲ្យជូតផ្ទះ ក្មេងៗតែមិនក្មេងប៉ុន្មានទេ អាយុ១៦-១៧ឆ្នាំហើយជំទង់ហើយ៧៥នោះ ។

វណ្ណៈ	ចឹងពេលបោសសម្អាតហើយនៅពេទ្យ១៧មេសាហ្នឹង គេបានរៀបចំយ៉ាងម៉េចដែរ?

គឿនៈ	ចាស!គេរៀបចំ តែខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ	ចឹងកាលហ្នឹងគេឲ្យមីងរៀនទៀតដែរ?

គឿនៈ	រៀន ។

វណ្ណៈ	ពីណាអ្នកបង្រៀន?

គឿនៈ	យាយនេះ មិនស្គាល់គេភ្លេចបាត់ហើយ ។

វណ្ណៈ	ចឹងមីងមានស្គាល់ប្រធានពេទ្យទេ?

គឿនៈ	ប្រធានពេទ្យថីមិនស្គាល់តាជួន ជឿន ។

វណ្ណៈ	ចឹងតាជួន ជឿន គាត់មានបង្រៀនមីងទេ?

គឿនៈ	ចាស!បង្ហាត់ទាំងអស់គ្នាហ្នឹង ទាំងពួកខ្ញុំអីបង្ហាត់ឲ្យរៀនពេទ្យរៀនអី ឲ្យចេះចាក់ថ្នាំឲ្យចេះមើលថ្នាំ កត់គ្រប់ ។

វណ្ណៈ	ចឹងតាដួន ជឿន ហ្នឹងល្បីណាស់គាត់ពូកែ?

គឿនៈ	ចាស!ពូកែ ណាស់តាហ្នឹង អ្នកជំងឺគាត់ចាក់ថ្នាំទៅស្រែយូយ អ្នកជំងឺថាដាច់ខ្យល់ឥឡូវហើយ គាត់ថាអត់អីទេ អត់អីមែន មិនដឹងម៉េចគាត់បានគាត់ចេះចឹង ថាអត់អីទេកុំភ័យមែនជាមែន ។

វណ្ណៈ	ចឹងបន្ទាប់ពីតាដួន ជឿន មានពីណាទៀតទៅ?

គឿនៈ	អត់ស្គាល់ ។

វណ្ណៈ	ចឹងមានស្គាល់ឈ្មោះ ពឿន កូនតាអៀង សារី នោះ?

គឿនៈ	អូ!ពឿន នោះស្គាល់ ។

វណ្ណៈ	ហ្នឹងកូនប្រសារ?

គឿនៈ	កូនប្រសារ ប្ដី នាង មិញ ស្គាល់តើ តែយើងត្រឹមស្គាល់តែយើងមិនបានរាប់អានគេទេ ដូចថាស្គាល់ៗណា គេអ្នកធំខ្ញុំមិនដឹងប្រវត្តិគេយ៉ាងម៉េច គ្រាន់ឮគេថា ថាតាមគេ ។

វណ្ណៈ	ចឹងបុគ្គលិកនៅពេទ្យ១៧មេសាហ្នឹង បើតាមមីងដឹងមានប៉ុន្មានរយនាក់ដែរ?

គឿនៈ	មានរាប់ពាន់ដឹងច្រើនគ្នាដែរ ។

វណ្ណៈ	ចឹងមានរាប់ពាន់នាក់?

គឿនៈ	ដឹងតែច្រើនដែលបុគ្គលិកណាស់ ។

វណ្ណៈ	ចឹងក្រោយមកទៀតនៅក្នុងពេទ្យហ្នឹង ប្រជាជនចេញអស់ពីក្រុងហើយ ចឹងក្រោយមកទៀតយើងត្រូវព្យាបាលពីណា ព្យាបាលកម្មករឬទាហានឬព្យាបាលកម្មាភិបាលពេលហ្នឹងពេលប្រជាជនចេញទៅអស់ ចឹងពេលហ្នឹងគេទុកសម្រាប់ព្យាបាលពីណាវិញ?

គឿនៈ	ព្យាបាលប្រជាជនគ្រប់ទូទាំងប្រទេស ។

វណ្ណៈ	ចឹង?

គឿនៈ	ពីតំបន់ណាពីខេត្តណាក៏ទៅពេទ្យរុស្ស៊ីហ្នឹងឯង ។

វណ្ណៈ	ចឹងប្រជាជនបានទៅដល់ហ្នឹងដែរ?

គឿនៈ	ចាស ។

វណ្ណៈ	ចឹងមិនព្យាបាលតែកម្មាភិបាលទេ?

គឿនៈ	អត់ទេ ទេខ្ញុំមិនសូវដឹងទេ រឿងកម្មាភិបាលនោះ ឃើញប្រជាជនទៅគ្រប់ខេត្ត ខ្ញុំសួរគេថានៅខេត្តណា ថាខ្ញុំនៅខេត្តបាត់ដំបង តានោះម្នាក់ណា ចឹងទេរឿងកម្មាភិបាលខ្ញុំមិនសូវចាប់អារម្មណ៍ទេ ព្រោះខ្ញុំនៅតាមកន្លែងដូចថាមួយជាន់ក្រុមខ្ញុំចេះនៅមួយក្រុមចេះទៅ គេក្រុមគេនៅក្រុមគេ ។

វណ្ណៈ៖ ចឹងកាលហ្នឹងដូចមីងរៀនបានតិចតួចដែលពេលយើងប្រើប្រាស់ថ្នាំ យើងធ្វើការចំណាំយ៉ាង ម៉េចដែរ?

គឿន៖ ចំណាំតើខ្វះៗ ។

វណ្ណៈ៖ ចឹងចំណាំខ្វះៗ?

គឿន៖ ចាស ។

វណ្ណៈ៖ ចឹងអត់មានចាក់ថ្នាំច្រឡំឲ្យថ្នាំច្រឡំអីទេ?

គឿន៖ អត់ទេ ។

វណ្ណៈ៖ ចឹងមានអ្នកជំងឺច្រើនទេ ពេលហ្នឹង?

គឿន៖ មានច្រើន ឆ្នាំ៧៥-៧៦-៧៧កាន់តែមានច្រើនទៀត ។

វណ្ណៈ៖ ចឹងភាគច្រើនអ្នកជំងឺទាំងអស់ហ្នឹងគាត់ឈឺអីជាពិសេស?

គឿន៖ ខ្ញុំមិនដឹងថា ឈឺអីទេ មានគ្រប់ផ្នែកគ្រប់ជំងឺ មហារីកថ្លើម មហារីកសាច់ ថ្លើម ក្រពះ គ្រប់ទាំងអស់ ។

វណ្ណៈ៖ ចឹងកាលហ្នឹងកើតមានជំងឺមហារីកដែរ?

គឿន៖ មាន ខ្ញុំមិនដែលឃើញទេ មហារីកធម្មតាតាមសាច់ តែមានតានោះមួយ នៅខាងបាត់ដំបង ហ្នឹង គាត់ថាឈឺគាត់ស្រែកយប់មួយថ្ងៃទល់មួយថ្ងៃយប់វាស់ព្រឹកមិនដែលបានដេកបាននៅ ទេ គាត់មិនចាស់ទេ ប្រហែលជាអាយុ៥០អីឯង តាជួន ជឿន គាត់ថាមហារីកថ្លើមឲ្យ គាត់វិញទៅ គាត់ថាចឹង គាត់និយាយផ្ទាល់ចឹងឯងឲ្យក្រុមពួកខ្ញុំហ្នឹង ឲ្យអឹមញ្ញើញទៅវិញចុះ វាមិនទំនងរស់ ឲ្យគាត់ទៅជួបជុំប្រពន្ធកូនគាត់វិញថាចេះ មិនមែនខ្ញុំទេ ក្រុមពួកខ្ញុំ ខ្ញុំមិន មែនមេក្រុមអីទេ ខ្ញុំនៅកូនគេទេ គេប្រាប់ចឹងឯង ខ្ញុំចំណាំបានចឹងឯង ។

វណ្ណៈ៖ ចឹងគេឲ្យទៅវិញចឹងមានឡានជូនទៅទេ?

គឿន៖ មានឡានជូនទៅ ដូចថាជូនដល់ត្រង់ណាទេ ដូចថាមិនកើតទេដឹង មានជូនចេញពីមន្ទីរពេទ្យ តែមិនដឹងត្រឹមណាទេ ឲ្យទៅណាខ្ញុំមិនដឹងទេ ឬគេរករបស់គេទៅខ្ញុំមិនសូវដឹងដែរ ឃើញ ចេញពីមន្ទីរពេទ្យ ឃើញមានឡានជូន ជូនតែមិនដឹងដល់ត្រឹមណាខ្ញុំមិនដឹងដែរ ខ្ញុំមិនបាន ចាប់អារម្មណ៍ទេ ។

វណ្ណៈ៖ ចឹងនៅក្នុងមន្ទីរពេទ្យជារៀងរាល់ថ្ងៃមានមនុស្សស្លាប់ច្រើនឬតិច?

គឿន៖ ចាស!ជារឿងធម្មតាទេ ជួនកាលមានជួនកាលក៏អត់ តែមិនអត់ទេ ក្នុងមួយៗថ្ងៃមានតាម អគ្គភាពគេ តាមសាលគេ មានតែកន្លែងខ្ញុំអត់មានស្លាប់ ព្រោះកន្លែងខ្ញុំនៅកន្លែងស្រាលអត់ សូវមានទេ ។

វណ្ណៈ: ចឹងកាលហ្នឹងបុគ្គលិកពេទ្យហូបចុកយ៉ាងម៉េចហើយអ្នកជំងឺហូបចុកយ៉ាងម៉េច?

គឿន: ហូបពិបាកណាស់ ។

វណ្ណៈ: ចឹងពេទ្យក៏ពិបាកដែរ?

គឿន: ចាស!ពិបាកហូបនំប៉័ងចែកគ្នាម្នាក់មួយកំណាត់ ហើយស្លត្រកួនខ្មៅ ត្រកួនស្ងោសាច់ជ្រូកខ្មៅចូលគ្នាតែម្តងក៏ហូបជាមួយនំប៉័ង បើគេមេៗទៅ គ្រាន់គេទុកនំប៉័ងអីទៅ បានស្គាល់គ្នាអ្នកទៅដឹកនំប៉័ងទៅបានហូបផ្អែត ម្នាក់បានតែមួយកំណាត់ ។

វណ្ណៈ: ចឹងអ្នកជំងឺក៏បានតិចដែរ?

គឿន: ចាស!ចឹងអត់មានបាយទេ ។

វណ្ណៈ: ដំបូងទេ?

គឿន: ទេ ដំបូងអី ទាល់យើងហ្នឹងរត់ហ្នឹងឯង តែពីដំបូងនោះយ៉ាប់ជាងនោះទៀត គេឲ្យហូបបាយលាយចេកខ្មៅៗហ្នឹង ។

វណ្ណៈ: ចឹងមានកន្លែងខ្លះគេឲ្យហូបស្រួលដែលតើ នៅភ្នំពេញហ្នឹង?

គឿន: ទេ ខ្ញុំមិនដែលបានស្រួលទេ ខ្ញុំនិយាយត្រង់ហើយដើងជាន់ព្រះធរណី និយាយមិនវៀចវេទេ ខ្ញុំថាយ៉ាងម៉េចចឹងហើយ ខ្ញុំថាយើងចេះហើយ មិនថាម៉េចទេណា ប៉ុល ពត តាម៉ុកតាមុាំងអី ខ្ញុំមិនភ្លេចគុណគេទេ គេមិនឲ្យអីយើងទេ តែមនុស្សដូចគ្នាចេះតែអាណិតគ្នាទៅមិនអាណិតអី គាត់មិនដែលឲ្យអីយើងទេ មិនដែលឲ្យពួកទេ និយាយឲ្យចំទៅតែជាមនុស្សដូចគ្នា ពួកគេថាតាម៉ុកៗ មិនដែលឃើញទេ តែជាមនុស្សដូចគ្នាក៏ចេះអាណិតទៅ ។

វណ្ណៈ: ចឹងកាលសម័យពីឆ្នាំកាលពីឆ្នាំ១៩៧៥ដល់៧៩ហ្នឹង បើនៅតាមស្រុកស្រែចម្ការប្រជាជនមានតំបន់ខ្លះគាត់ហូបបានគ្រាន់បើ តែមានកន្លែងខ្លះអត់រហូតដល់ស្លាប់ តែភាគច្រើនខ្ញុំជួបកម្មាភិបាលពេទ្យ ជាពេទ្យ ជាកម្មកររោងចក្រ ជាយោធានៅទីក្រុងភ្នំពេញហ្នឹង ភាគច្រើនគាត់និយាយថាហូបបាយបានគ្រប់គ្រាន់ដែរ?

គឿន: ចាស ។

វណ្ណៈ: តែមីងអត្តភាពមីងហូបមិនសូវបាន?

គឿន: អត់សូវបាន ។

វណ្ណៈ: តែខ្លះនៅពេទ្យ៧មករាគេថាហូបបាយអីចឹង ពេទ្យជាមួយគ្នានៅភ្នំពេញហ្នឹង?

គឿន: ចាស ។

វណ្ណៈ: ចឹងកន្លែងមីងហូបនំប៉័ងរហូតដល់៧៩?

គឿនៈ	ចាស!ហូបនំប៉័ងមានបាយខ្លះដែរ ចានប៉ុននេះមានគ្នា៨នាក់មួយគុ ហើយអត់មានថែមទេ បើបានទៅដាំបាយធ្វើចុងភៅបានហូបឆ្អែត ហូបបានមួយឆ្អែតតែម្ដង បើយើងបានធ្វើចុងភៅបានបាយក្ដាំងអី ។

វណ្ណៈ	ចឹងមីងមានធ្លាប់បានធ្វើចុងភៅទេ?

គឿនៈ	ខ្ញុំមានវេន មួយក្រុមមួយវេនៗ មកព្យាបាលមួយវេនចឹងទៅ ពេលបានទៅដាំបាយអរណាស់ ។

វណ្ណៈ	បាទ ។

គឿនៈ	ចាស!អរពួកខ្ញុំអរ បានហូបឆ្អែត ។

វណ្ណៈ	ចឹងកាលហ្នឹងមីងចេះព្យួរសេរ៉ូម ចេះចាក់ថ្នាំអីទេ?

គឿនៈ	ចេះ ។

វណ្ណៈ	ចឹងគេមានបង្ហាត់បង្រៀនយើងដែរ?

គឿនៈ	ចាស ។

វណ្ណៈ	ចឹងយើងរៀនចាក់ថ្នាក់ព្យួរសេរ៉ូម ចាក់ថ្នាក់អីហ្នឹងយើងរៀនប៉ុន្មានខែដែលបានចេះ?

គឿនៈ	អត់មានបង្រៀនអីទេ ដូចថាយើងនៅក្រុមណាចឹងមានអ្នកចេះមួយពីរចឹង គេបង្ហាត់យើងទៅណាស់ ពេលគេចាក់ថ្នាំគេហៅមក ដូចថាខ្ញុំមិនចេះមកមីអូនឬមួយមិត្តនេះមិត្តនោះមកចាក់អានេះចេះទៅ ហើយយើងក៏ចេះចាក់តាមទៅ យើងក៏ចេះទៅ តែយើងមិនចេះណាស់ណាទេ គ្រាន់យើងអាចព្យាបាលមួយក្រុមគ្រួសារយើងណា ។

វណ្ណៈ	ចឹងកាលហ្នឹងថ្នាំទាំងអស់ហ្នឹងមកពីខាងណាវិញ?

គឿនៈ	មកពីចិន ។

វណ្ណៈ	ចឹងចិនជួយយើងដែលកាលហ្នឹង?

គឿនៈ	ចាស ។

វណ្ណៈ	ឥឡូវចិនជួយយើងដែរ?

គឿនៈ	ចាស ។

វណ្ណៈ	ចឹងមីងកាលហ្នឹងមានឃើញជនជាតិចិនមកបង្រៀនយើងនៅមុខវិជ្ជាពេទ្យហ្នឹងទេ មីងមានឃើញជនជាតិចិនទេ?

គឿនៈ	ឃើញ ។

វណ្ណៈ	មានចិនមានអីដែរ?

គឿនៈ	មាន ។

វណ្ណៈ៖ ចឹងមានចិនធ្លាប់បង្រៀនដែរ?

គឿន៖ ចាស!មានចិនបង្រៀនហើយមានខ្មែរយើងចេះចិនចេះអី មានអ្នកបកប្រែដើរតាមជាមួយចិន ។

វណ្ណៈ៖ ចឹងមានអ្នកបកប្រែ?

គឿន៖ ចាស ។

វណ្ណៈ៖ ចឹងមីងនៅពេទ្យ១៧មេសាហ្នឹងរហូតដល់វៀតណាមចូលអត់មានការផ្លាស់ប្ដូទេ?

គឿន៖ ចាស ។

វណ្ណៈ៖ ចឹងនៅក្នុងអន្តភាពមីងកាលសម័យហ្នឹងមានការចោទគ្នាទៅវិញទៅមក ហើយមានអ្នកខ្លះត្រូវបានចាប់ខ្លួនអីទេ?

គឿន៖ ចាប់មានរាល់ថ្ងៃ ។

វណ្ណៈ៖ ចឹងមានចាប់បុគ្គលិកពេទ្យដែរ?

គឿន៖ ចាប់ ។

វណ្ណៈ៖ ចឹងអ្នកដែលគេចាប់ហ្នឹង មីងមានដឹងថាអ្នកហ្នឹងខុសអីទេ?

គឿន៖ ខ្ញុំអត់ដឹងទេ ស្រាប់តែព្រឹកឡើងបាត់អ្នកនេះអ្នកនោះ គេថាចាប់ហើយ មិនដឹងជាចាប់យកទៅណាមិនដឹងដែរ គេមេៗណាខ្ញុំមិនសូវដឹងទេ ។

វណ្ណៈ៖ ចឹងចាប់តែមេៗទេ?

គឿន៖ ចាស!មានត្រឹមកូនក្រុមចាប់ខ្លះដែរ និយាយខុសហ្នឹង ខ្ញុំចំណាំបានថានិយាយខុស គ្រាន់តែនិយាយថាដាំៗមិនឲ្យសល់ដីមួយចង្អាមលើថ្មក៏ដាំលើភ្នំក៏ដាំ គ្នាចឹងណាក៏ចាប់គ្នាដែរ ឆ្នាំ៧៧ចាប់ណាស់ហើយ ។

វណ្ណៈ៖ បែបគាត់ចង់និយាយថា ដាំគ្នាសល់ដីតែនៅតែហូបមិនបានឆ្អែត?

គឿន៖ ចាស ។

វណ្ណៈ៖ ចឹងគេថាយើងដឹងដាក់គេ?

គឿន៖ ចាស ។

វណ្ណៈ៖ ចឹងមីងនៅឆ្នាំ១៩៧៧-៧៨ចឹងប្រទេសយើងមានសង្គ្រាមជាមួយប្រទេសវៀតណាមចឹងមានយោធាមកដេកសម្រាកព្យាបាលនៅពេទ្យ១៧មេសាហ្នឹងដែលអត់ មីងមានបានព្យាបាលអ្នករបួសអត់?

គឿន៖ អត់មានទេ ពេទ្យដូចខ្ញុំថាមិញហ្នឹងអត់មានទេ គេមានពេទ្យយោធាពេទ្យព-៩០ប៉ុន្នានទេ ។

វណ្ណៈ៖ ចឹងពេទ្យព-៩៨?

គឿនៈ ចាស!អីនោះវិញទេ មកពេទ្យកងទ័ពនោះ ។

វណ្ណៈ ចឹងពេទ្យរុស្ស៊ីហ្នឹងព្យាបាលតែប្រជាជនទេ?

គឿនៈ ចាស!តែប្រជាជនទេ ។

វណ្ណៈ មានកូនក្មេងអីទេ?

គឿនៈ មានសព្វគ្រប់ ។

វណ្ណៈ ចឹងបុគ្គលិកពេទ្យហ្នឹងមានចាប់មនុស្សដែរ?

គឿនៈ មាន ។

វណ្ណៈ ចឹងមីងមានដែលឃើញអ្នកធំទៅទស្សនៈកិច្ចពេទ្យហ្នឹង មីងមានឃើញពីណាខ្លះទេ?

គឿនៈ ពួកខ្ញុំដូចជាអត់ឃើញទេ ។

វណ្ណៈ ចឹងមានឃើញប្រពន្ធតាអៀង សារី គាត់មានទៅហ្នឹងទេ?

គឿនៈ ឃើញយាយនោះ ដើរក្រគេក្រគឺតាមមន្ទីរពេទ្យហ្នឹង ពួគេនិយាយថាប្រពន្ធអៀង សារី ។

វណ្ណៈ មីងមានស្គាល់ឈ្មោះគាត់ទេ?

គឿនៈ ស្គាល់តែយើងមិនដែលហៅគេ គេអ្នកធំ ។

វណ្ណៈ ឈ្មោះអីទៅ?

គឿនៈ ឈ្មោះ អៀង ធិរិទ្ធ ឃើញគាត់ដើរចុះយើងគ្រាន់តែមើលគេ យើងប្រជារាស្ត្រ បើកូនគេដើរតាមមើលតាមក្រុមអីកូនគេហ្នឹងឯង តាមសាលគេដូចថាយើងជាន់ទី១មួយក្រុមគេដើររកមើលគេដើររកសរសេរ សួរយើងប្រវត្តិរូបមេក្រុមខ្ញុំចេះ គេសរសេរទៅខ្ញុំក៏ចេញដូនកាលមិនបានស្តាប់និងគេទេ មិនដឹងគេនិយាយអី យើងមិនដឹងដែរ ។

វណ្ណៈ ចឹងមីងឃើញគាត់ មីងគិតថា មើលទៅគាត់ជាមនុស្សមឺងម៉ាត់ឬមើលទៅជាមនុស្សគួរឲ្យភ័យខ្លាចឬយ៉ាងម៉េចអៀង ធិរិទ្ធ ហ្នឹង?

គឿនៈ ទេ ទៅមិនឲ្យភ័យទេ ។

វណ្ណៈ ចឹងគាត់ជាមនុស្សស្លូតដែរ?

គឿនៈ ចាស!តែគាត់មាត់ឡូឡាដែរ តែដូចថាមិនភ័យ ខ្ញុំមិនដែលភ័យទេ គេនៅតែគេ យើងនៅតែយើង ។

វណ្ណៈ ចឹងមីងកាលហ្នឹងអត់មានឡើងជាប្រធានអីទេ?

គឿនៈ ទេ!មិនដែលមានស្អីគេទេខ្ញុំ ។

វណ្ណៈ ក្រៅពីអៀង ធិរិទ្ធ មានដែលឃើញអៀង សារី ប៉ុល ពត នួន ជា ខៀវ សំផន ទៅមើលទេ?

គឿនៈ ខ្ញុំមិនដែលឃើញគេទេ ។

វណ្ណៈ ចឹងនៅក្នុងមន្ទីរពេទ្យហ្នឹងមានប៉ុន្មានថ្ងៃឬខែបានប្រជុំគ្នាម្តង ប្រជុំរឿងនយោបាយឬប្រជុំប្រាប់ព្យាបាលអីហ្នឹង គេមានដែលខស្សរាហ៍ប្រជុំដែលអត់?

គឿនៈ ប្រជុំក្នុងមួយថ្ងៃពេលយប់ប្រជុំលើកគុណសម្បត្តិគុណវិបត្តិគ្រប់គ្នារាល់ថ្ងៃ ។

វណ្ណៈ ចឹងប្រជុំគុណសម្បត្តិគុណវិបត្តិហ្នឹង?

គឿនៈ ចាស ៗ!អ្នកនេះបានធ្វើអី អ្នកនោះបានធ្វើអី ចឹងម្នាក់ម្តងៗមួយពួកប្អូនទាក់ប្រាំនាក់ចឹងធ្វើម្នាក់ម្តងៗចឹងទៅ ។

វណ្ណៈ ចឹងលើករាល់ថ្ងៃ?

គឿនៈ លើករាល់ថ្ងៃ ។

វណ្ណៈ ចឹងបើអ្នកណាមានកំហុសបន្តិចបន្តួចអីគេចាប់តែម្តងឬគេនៅមានកសាងដែរ?

គឿនៈ អត់ទេ កសាង ។

វណ្ណៈ ចឹងមីងមានដឹងថា គេចាប់បុគ្គលិកពេទ្យហ្នឹងចាប់យកទៅណា គេចាប់យកទៅទួលស្លែងមីងមានដឹងទេ?

គឿនៈ ខ្ញុំឮគេនិយាយថា យកទៅគុកព្រៃស ។

វណ្ណៈ និយាយទៅមីងមានដែលឃើញគេចាប់ផ្ទាល់ទេ?

គឿនៈ អត់ទេ ឃើញបាត់ៗតែម្តង មិនដែលឃើញគេចាប់ផ្ទាល់ៗទេ ។

វណ្ណៈ ចឹងពីឆ្នាំ១៩៧៥ដល់៧៩ហ្នឹង នៅក្នុងចន្លោះហ្នឹងមីងរៀបការហើយនៅ?

គឿនៈ នៅទេ ។

វណ្ណៈ ចឹងពេលវៀតណាមចូលមកនៅឆ្នាំ១៩៧៩ មីងរត់ទៅណាវិញ រត់តាមផ្លូវណា?

គឿនៈ រត់តាមផ្លូវជាតិលេខ៤ ។

វណ្ណៈ ចឹងកាលហ្នឹងអ្នកជំងឺនៅក្នុងមន្ទីរពេទ្យយើងដាក់តាមរទេះភ្លើងទៅជាមួយឬមួយយើងរត់យករួចខ្លួន?

គឿនៈ អត់ដឹងទេ អ្នកជំងឺពេលជ្រួលច្របល់ហើយពេទ្យទៅផ្សេងហើយ អ្នកជំងឺមិនដឹងជាទៅខាងខ្ញុំមិនសូវដឹងដែរ មិនសូវចាប់អារម្មណ៍រឿងអ្នកជំងឺទេ យើងរៀបខោអាវរៀងៗខ្លួន ។

វណ្ណៈ ចឹងកាលហ្នឹងមីងយ៉ាងម៉េចបានជាមិនរត់សំដៅមកស្រុកកំណើតវិញឆ្ងាយពេកឬក៏យ៉ាងម៉េច?

គឿនៈ ចាស!គេមិនឲ្យមក ។

វណ្ណៈ ចឹងមីងរត់តាមអង្គភាព?

គឿនៈ ចាស! រត់តាមអង្គភាព។

វណ្ណៈ: ចឹងដំបូងមីងជិះអីទៅ?

គឿនៈ ខ្ញុំជិះឡានដឹកឈើ។

វណ្ណៈ: ជិះឡានដឹកឈើដល់ត្រឹមណាបានចុះ?

គឿនៈ ដល់កំពង់ស្ពឺអស់ប្រេងបណ្ដោយ។

វណ្ណៈ: ចឹងអស់ប្រេងចុះដើរ?

គឿនៈ ចុះដើរកាត់តាមអមលាំងព្រៃ ក្រាំងស្រម៉ ត្បែងខ្ពស់មកតាមនោះហើយ។

វណ្ណៈ: ចឹងតាមភ្នំរហូត?

គឿនៈ ចាស។

វណ្ណៈ: ចឹងមីងមានកាន់កាំភ្លើងដែរ?

គឿនៈ អត់មាន។

វណ្ណៈ: ចឹងកាលហ្នឹងមានខ្លាចអីបេះតែរត់ៗទៅ?

គឿនៈ ខ្លាចវៀតណាម។

វណ្ណៈ: ចឹងពេលរត់ហ្នឹងមានជួបប្រជាជនតាមផ្លូវច្រើនដែរ?

គឿនៈ ចាស! អត់មានជួបទេ មិនដឹងជម្លៀសទៅណាអស់ ស្ងាត់ផ្ទះនីមួយៗ។

វណ្ណៈ: ចឹង?

គឿនៈ ចាស! បើកំពង់ស្ពឺឃើញផ្សារហើយអត់មានឃើញមនុស្ស។

វណ្ណៈ: និយាយទៅរត់ទាំងអស់គ្នា?

គឿនៈ និយាយរួមគេអ្នករត់មុនយើង យើងមកក្រោយតគ្នា។

វណ្ណៈ: ចឹងតាមផ្លូវមានបានអីហូបទៅ.?

គឿនៈ តាមផ្លូវមានអង្ករស្ពាយរៀងខ្លួន អ្នកណាមិនកើតជួយហូបរួមគ្នាទៅ។

វណ្ណៈ: ចឹងទំរាំដល់ព្រំដែនមិនអស់ហើយអង្ករមានតែមួយសំពាយហ្នឹង?

គឿនៈ ចាស! ឃើញស្រូវប្រជាជននៅក្នុងជង្រុកយើងយកបុកដាក់ទៃទៅ។

វណ្ណៈ: ចឹងពេលមីងរត់តាមផ្លូវហ្នឹងឃើញមានមនុស្សស្លាប់អីដែរ?

គឿនៈ ខ្ញុំអត់មានរត់តាមផ្លូវទេ ខ្ញុំរត់តាមព្រៃតែម្ដង។

វណ្ណៈ: រត់តាមព្រៃ នៅក្នុងព្រៃឃើញមានមនុស្សស្លាបទេ?

គឿនៈ មានស្លាប់ដោយអត់មានទឹក ស្លាប់ដោយគេវាយចោល គេហៅអីទាហានប៉ាភគេវាយមនុស្សចោល។

វណ្ណៈ    ៧៩ហ្នឹងមានទាហានប៉ុលពតហើយមិនទាន់មានទេ?

គឿនៈ    ទាហានប៉ុលពតពួកគេនិយាយទេ ។

វណ្ណៈ    កាលហ្នឹងរត់មកត្រឹមកំពង់ស្ពឺមានទាហានខាងនិរតីវាយពួកប្អូន?

គឿនៈ    អត់មានទេ ខាងនោះ ត្រឹមកំពង់ស្ពឺនោះមិនទាន់មានទេ ខ្ញុំរត់មកក្រោយអមលាំងនេះទៀត ដល់ភ្នំទិកវ៉ាល់នោះបានឃើញមានទាហានប៉ុលពត មិនដឹងជាទាហានអីទេ ខ្ញុំពួកគេថាទាហានប៉ុលពត សម្លាប់មនុស្ស ដើរដាច់ប្អូនទៅប្រាំនាក់គេវាយចោលអស់ខ្ញុំនិយាយត្រង់ៗទេខ្ញុំ ខ្ញុំមិនបាន ធ្វើអីមែន ។

វណ្ណៈ    ចឹងមីងរត់រយៈពេលហ្នឹងទំរាំដល់ព្រំដែនហ្នឹងមានពេលប៉ុន្មានខែដែរ?

គឿនៈ    ទេ ដូចជាមិនដល់ខែទេ មិនដល់កន្លះខែទេ ។

វណ្ណៈ    ចឹង?

គឿនៈ    ខ្ញុំនៅភ្នំទិកវ៉ាល់ហ្នឹងយូរដែរនៅ៥ថ្ងៃ១០ថ្ងៃដឹង ។

វណ្ណៈ    រួចហើយចេញដំណើរទៀតទៅ?

គឿនៈ    ចេញមកខេត្តពោធិសាត់ ។

វណ្ណៈ    មានគ្នាប៉ុន្មាននាក់?

គឿនៈ    គ្នាច្រើនណាស់ រាប់មិនអស់ តាំងប្រជាជនអីអាចរាប់ម៉ឺននាក់ រាប់សែនមិនដឹងឃើញ ប្រជាជនស្ពាយកូនរែកកូនពីខាងបូព៌ាខាងអីទាំងអស់ ទៅកកនៅពាយ័ព្យទាំងអស់ ។

សុវណ្ណៈ  ខ្លាចទាហានវៀតណាមហ្នឹងខ្លាចយ៉ាងម៉េចមីង?

គឿនៈ    ខ្លាចគេថាតែអុងៗ បើមេគេថាចុះហើយយើងប្រជារាស្ត្រជឿតាមគេខ្លាច ។

វណ្ណៈ    មីងស្គាល់តែអុងដែរ?

គឿនៈ    ទេ មិនស្គាល់ទេ ពួកគេថា ។

វណ្ណៈ    ចឹងពេលមីងរត់ដល់ជាយដែនមីងរត់ទៅដល់មុំណា   ពេលមីងរត់ទៅដល់ជាយដែនហ្នឹងនៅ ខាងណា នៅខាងម៉ាឡៃឬនៅខាងអន្លង់វែងឬនៅខាងណា រត់មកដល់ណា?

គឿនៈ    ខ្ញុំរត់មកដល់ពាយ័ព្យស្រុកបាកាន ។

វណ្ណៈ    អាពោធិសាត់ទេ មិនទាន់ដល់ព្រំដែនទេ?

គឿនៈ    ចាស!ខ្ញុំមិនទាន់ដល់ទេ ។

វណ្ណៈ    ចឹងខ្ញុំចង់និយាយថា ចេញពីពោធិសាត់ទៀត?

គឿនៈ    ចេញពីពោធិសាត់នោះយួនវាគៀបបានទាំងអស់ ។

វណ្ណៈ    គ្នាបានទាំងអស់ធ្វើម៉េចទៀតទៅ?

គឿនៈ គៀបានទាំងអស់ឲ្យមកវិញទាំងអស់ ។

វណ្ណៈ ឲ្យមកខាងណាវិញ ។

គឿនៈ មានអ្នកបកប្រែឲ្យត្រឡប់មកវិញផ្លូវកំពង់ឆ្នាំង ផ្លូវជាតិលេខ៥ហ្នឹង មកទាំងអស់ខ្ញុំឆ្លងមក សៀមរាបទន្លេមួយនោះ ខ្ញុំមកតាមនោះឯង៧៩ ។

វណ្ណៈ ចឹងពេលវៀតណាមស្ទាក់បានហើយ ប្រាប់ថាអ្នកណានៅស្រុកណាឲ្យទៅនៅស្រុកនោះវិញ ចឹង?

គឿនៈ ចាស!ប្រាប់ថា អ្នកណានៅណាឲ្យទៅនៅស្រុកនោះវិញ អ្នកបកប្រែនោះស្រីផងប្រុសផង កាលហ្នឹង ។

វណ្ណៈ គេប្រាប់ថា អត់មានសម្លាប់អីទេ?

គឿនៈ អត់ទេ ។

វណ្ណៈ គេមាននិយាយប្រាប់ដែរ?

គឿនៈ គេនិយាយប្រាប់ថា នៅស្រុកណាឲ្យទៅស្រុកនោះវិញ ។

វណ្ណៈ អត់មានពីណាសម្លាប់ចោលអីទេ?

គឿនៈ ចាស ។

វណ្ណៈ តែមីងនៅតែមិនទៅ?

គឿនៈ ខ្ញុំទៅ៧៩ខ្ញុំទៅវិញតើ ។

វណ្ណៈ មីងទៅដល់ផ្ទះ?

គឿនៈ ខ្ញុំទៅដល់ផ្ទះវិញ ។

វណ្ណៈ ចឹងអត់មានបានទៅដល់ជាយដែនទេ?

គឿនៈ អត់ទេ ទៅនៅផ្ទះយូរ ។

សុវណ្ណៈ កាលមីងនៅពោធិសាត់មីងនៅម្តុំណា?

គឿនៈ កាលហ្នឹងនៅស្រុកបាកាន ។

វណ្ណៈ ទៅនៅស្រុកបាកានទៅដល់នៅបានប៉ុន្មានខែប៉ុន្មានថ្ងៃ?

គឿនៈ គ្មានប៉ុន្មានទេនៅជាងមួយអាទិត្យ វៀតណាមចាប់បាន ។

វណ្ណៈ ចឹងមីងបានទៅដល់ស្រុកកំណើតវិញឆ្នាំ៧៩ហ្នឹងតែម្តង?

គឿនៈ ចាស!ឆ្នាំ៧៩មកដល់ភូមិខ្ញុំរស់នៅ ។

វណ្ណៈ ចឹងយ៉ាងម៉េចទៀតទៅ មីងមកដល់ភូមិវិញមីងរៀបការឬមួយចេញទៅណាទៀត?

គឿនៈ មិនទាន់រៀបការទេ ។

វណ្ណៈ	ចឹងមីងទៅណាទៀត ពេលមីងមកដល់ផ្ទះហើយ?

គឿន៖	មកដល់ផ្ទះហើយឆ្នាំ១៩៨១ខ្ញុំចេញមកនេះទៀត ចេញមកបន្ត។

វណ្ណៈ	យ៉ាងម៉េចមីងមកដល់ផ្ទះហើយយ៉ាងម៉េចបានមានចិត្តចង់ទៅព្រៃទៀតចឹង?

គឿន៖	កាលហ្នឹងពួក១៧ពួកនៅតាមភូមិ ពួកជម្លៀសពីភ្នំពេញគេឃើញ គេថាយើងជា ប៉ុល ពត គេរករឿងដែលណាស់។

វណ្ណៈ	ចឹងកាលហ្នឹងគេរករឿងដែរ?

គឿន៖	ចាស។

វណ្ណៈ	ចឹងមីងមិនប្រាប់គេថា ខ្ញុំមានធ្វើអីកាលហ្នឹងខ្ញុំធ្វើពេទ្យតូចតាចទេ?

គឿន៖	ប្រាប់គេ តែគេមិនរករឿងដល់សម្លាប់អីទេ គ្រាន់តែដឺៗដូចថាដឺឲ្យយើងណាឃើញថា ប៉ុល ពត ចេះ ស្លៀកពាក់អីកាត់សក់ខ្លី គ្រាន់តែឃើញគេដឹងបាត់ហើយពួកខ្ញុំនោះ។

វណ្ណៈ	ចឹងមីងគិតក្នុងចិត្តតយយ៉ាងម៉េចទៅ ពេលគេនិយាយចឹងមីង?

គឿន៖	គិតថា ខ្លាច។

វណ្ណៈ	ខ្លាចពីណាគេ?

គឿន៖	ខ្លាចពួក១៧មេសាហ្នឹង ដែលគេជម្លៀសហ្នឹង ពួកប៉ុល ពត ជម្លៀសមកគេឃើញថាយើង ប៉ុល ពត ចេះ គេរករឿង។

វណ្ណៈ	ចឹងអ្នក១៧មេសាហ្នឹងពេលឆ្នាំ៨១ហើយហ្នឹង មិនទាន់មករកស្រុកកំណើតវិញទេ?

គឿន៖	ចាស!គេទៅស្រុកវិញអស់ហើយពួកហ្នឹង ពួកនៅច្បារអំពៅ ពួកនៅភ្នំពេញ។

វណ្ណៈ	ចឹងមីងខ្លាចអីទៀត?

គឿន៖	ខ្ញុំចេះតែខ្លាចហើយណាស់។

វណ្ណៈ	ចឹងមីងចូលព្រៃវិញនៅឆ្នាំ១៩៨១ហ្នឹង មីងចូលព្រៃនៅម្តុំណាវិញ?

គឿន៖	ខ្ញុំមកនៅប្រកជុំបរុននេះ។

វណ្ណៈ	ជុំបរុនហ្នឹងគេហៅប្រក១០០០ប៉ុន្មាន?

គឿន៖	ប្រក១០០៣។

វណ្ណៈ	១០០៣ហ្នឹងពីណាគ្រប់គ្រងនៅហ្នឹង?

គឿន៖	មានតាហឿន។

វណ្ណៈ	តាហឿន ហើយមានពីណាទៀត មានឃើញតាម៉ុកទេនៅហ្នឹង?

គឿន៖	១០០៣ហ្នឹង តាម៉ុក។

វណ្ណៈ	ចឹង១០០៣ហ្នឹងតាម៉ុកគាត់នៅ?

គឿនៈ ចាស ។

វណ្ណៈ តាហឿន គាត់ប្រធានកងពលទេចឹង?

គឿនៈ ចាស ។

វណ្ណៈ ចឹងពេលមីងនៅ១០០៣ហ្នឹង មីងបានរៀបចំគ្រួសារដែលឬនៅទេ?

គឿនៈ ខ្ញុំយកតាមខ្ញុំនេះ ។

វណ្ណៈ ចឹងមីងការនៅឆ្នាំ១៩៨១ហ្នឹងដែរ?

គឿនៈ ខ្ញុំយក៨២ ។

វណ្ណៈ ពេលការកាលហ្នឹងមានភ្លេងការមានចាស់ទុំដែលទេ?

គឿនៈ មានភ្លេងមកពីណា ។

វណ្ណៈ ចឹងចាប់គូរ?

គឿនៈ មិនចាប់ទេ ឈប់មានចាប់គូរអីហើយ តែការអត់មានភ្លេង ។

វណ្ណៈ ចឹងការមានសែនដែរ?

គឿនៈ ចាស!មានសែន ។

វណ្ណៈ គេឲ្យយើងសែនដែល?

គឿនៈ ចាស!មានអី ។

វណ្ណៈ ជុបលៀងចឹងទៅ?

គឿនៈ ចាស!បាយឯកជនធម្មតា ។

វណ្ណៈ មានពីណាចូលរួមដែរ?

គឿនៈ អត់ដឹងដែរ ។

វណ្ណៈ មានតាហឿន អីដែរ?

គឿនៈ ទេ ។

វណ្ណៈ ចឹងកាលហ្នឹងគ្រួសារមីងគាត់ធ្វើយោធា?

គឿនៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងគាត់មានឋានៈអីដែរ កាលដែលគាត់ការជាមួយមីងហ្នឹង?

គឿនៈ ខ្ញុំអត់ដឹង គាត់នៅពាណិជ្ជទេ តាហ្នឹង ។

វណ្ណៈ គាត់នៅពាណិជ្ជកម្ម?

គឿនៈ គាត់នៅពាណិជ្ជលក់ ។

វណ្ណៈ អាហ្នឹងហៅពាណិជ្ជកម្ម?

គឿនៈ ចាស ។

វណ្ណៈ: ចឹងកាលហ្នឹងមីងការហើយគេឲ្យជួយជញ្ជូនគ្រាប់ដែលឬមួយគេឲ្យនៅសមរភូមិក្រោយ?

គឿនៈ ខ្ញុំនៅក្រោយ ។

វណ្ណៈ: ចឹងនៅក្រោយគេឲ្យមីងធ្វើអីខ្លះបិតចំរូងឬធ្វើអី?

គឿនៈ អត់មានធ្វើអីទេ នៅធម្មតា ។

វណ្ណៈ: ចឹងរបបគេបើកឲ្យ?

គឿនៈ គេបើកឲ្យ ។

វណ្ណៈ: ចឹងគេអត់មានឲ្យយើងធ្វើសោះតែម្តងឬគេឲ្យយើងធ្វើការបន្តិចបន្តួចដែរ?

គឿនៈ ចាស!គេមានឲ្យធ្វើអី យើងធ្វើស្រែចម្ការហូបខ្លួនឯង ។

វណ្ណៈ: ចឹងកាលនៅ១០០៣ហ្នឹង?

គឿនៈ ចាស!កាលហ្នឹងដាំដំឡូងលក់ឲ្យថៃ ។

វណ្ណៈ: ចឹងគ្រួសារមីងក៏អត់មានចុះទៅខាងមុខដែលគាត់នៅខាងពាណិជ្ជកម្មខាងឃ្លាំង?

គឿនៈ ទេ គាត់នៅខាងឃ្លាំង ។

វណ្ណៈ: ចឹងប្រជាជននៅខាង១០០៣ហ្នឹងមានច្រើនគ្រួសារដែរ?

គឿនៈ មានច្រើន ។

វណ្ណៈ: ប្រហែលជាប៉ុន្មានពាន់នាក់?

គឿនៈ មិនដឹងទេខ្ញុំ ខ្ញុំដឹងថាច្រើន ។

វណ្ណៈ: ចឹងមីងមានដឹងថាសង្គ្រាមខាងរដ្ឋាភិបាលសហការជាមួយទាហានវៀតណាមវាយជាមួយ
ខ្មែរក្រហមមីងមានដឹងទេ?

គឿនៈ ដឹងតើ ។

វណ្ណៈ: តែមីងមិនបានឡើងវាយជញ្ជូនគ្រាប់អីទេ?

គឿនៈ ចាស ។

វណ្ណៈ: ចឹងនៅប្រក១០០៣ហ្នឹង យ៉ាងម៉េចបានគេដាក់ថា១០០៣ហ្នឹង?

គឿនៈ ខ្ញុំមិនដឹងទេ ។

វណ្ណៈ: ចឹងប្រកដុបរុន១០០៣ហ្នឹងនៅក្នុងដីខ្មែរឬដីថៃ?

គឿនៈ ដីថៃ ។

វណ្ណៈ: តែជាប់ដីខ្មែរដែលឬមិនមែនទេ.?

គឿនៈ ចាស!ជាប់ដីខ្មែរដែលអីខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ	ចឹងក្រោយមកទៀតមីងមានចេញពី១០០៣ទៅណាទៀតទេ?

គឿនៈ	ដូចថាមកក្រោម ចុះមកក្រោម ។

វណ្ណៈ	មីងចុះមកឆ្នាំណា?

គឿនៈ	ខ្ញុំចុះមកឆ្នាំណាទេ ។

វណ្ណៈ	ចឹងអត់មានដឹងឆ្នាំទេ?

គឿនៈ	អត់ដឹងទេ ។

វណ្ណៈ	ចឹងមីងមានដឹងថាតាម៉ុក ធ្វើដូវអីឆ្នាំណាដែរ មីងធ្លាប់ស្គាល់តាម៉ុក ទេ?

គឿនៈ	ធ្លាប់ឮតែគេថាទេ ។

វណ្ណៈ	ចឹងមិនដែលស្គាល់គាត់ទេ?

គឿនៈ	ចាស ។

វណ្ណៈ	ចឹងមិនដែលឃើញមុខគាត់ទេ?

គឿនៈ	ឃើញពីចម្ងាយ ឃើញគេថានោះឡានតាម៉ុកៗ ថាតាមគេទៅ ។

វណ្ណៈ	ចឹងអត់មានបានមើលគាត់ផ្ទាល់ថា ចរិកគាត់យ៉ាងម៉េចទេ?

គឿនៈ	អត់ទេ មិនដែលទេ ។

វណ្ណៈ	ចឹងតាម៉ុក គាត់មានបានកសាងអីខ្លះដែលនៅតំបន់អន្លង់វែងត្រពាំងប្រាសាទអីហ្នឹង គាត់មានបានជួយកសាងអីខ្លះដែរ?

គឿនៈ	ខ្ញុំអត់ដឹងទេ ។

វណ្ណៈ	ចុះដូវ ស្ពាននេះឮគេនិយាយថា តាម៉ុក ធ្វើ?

គឿនៈ	ដឹងអី ខ្ញុំមិនដឹងទេ ។

វណ្ណៈ	ចឹងកាលមីងចុះមកនៅខាងក្រោមនេះ មីងមកនៅភូមិនេះតែម្តងឬមីងនៅកន្លែងណាផ្សេង?

គឿនៈ	ខ្ញុំនៅក្រោយនេះ ។

វណ្ណៈ	ចុះមកនៅដំបូងមកនៅភូមិអី?

គឿនៈ	គេហៅភូមិហ្នឹងឯង តែនៅព្រៃខាងក្រោយ មិនឆ្ងាយអីណា នោះនៅខាងក្រោយស្រែផ្ទះគេប្រហែលដីកន្លះគីឡូតែប៉ុណ្ណឹង ។

វណ្ណៈ	ចឹងកាលមកដល់ដំបូងមានព្រៃឈើធំៗឬវាលចឹង?

គឿនៈ	ដើមឈើមាន សុទ្ធព្រៃណាតាមហ្នឹង ។

វណ្ណៈ	មានសត្វព្រៃក៏មានអីក៏មានដែរ?

គឿនៈ	ចាស ។

វណ្ណៈ ហើយមានមនុស្សឈឺចាញ់ស្លាប់អីដែលកាលហ្នឹង?

គឿន: អត់ទេ ។

វណ្ណៈ ចឹងពេលមីងមកដល់ដីបូងមីងមានបានធ្វើផ្ទះធំហើយឬនៅឬមួយ នៅផ្ទះតូចទេ?

គឿន: ផ្ទះខ្ញុំដីបូងធំដែរ ផ្ទះខ្ញុំមានពីរខ្នងដែលតើ ។

វណ្ណៈ ចឹងក្រោយមកទៀតមានរត់លូតទៀតទេ ពេលចុះមកនៅហ្នឹងហើយ?

គឿន: អត់មានទេ ។

វណ្ណៈ ចឹងអត់មានទេ?

គឿន: ចាស ។

វណ្ណៈ ចឹងក្រោយមកទៀតមីងមានដឹងថា មានព្រឹត្តិការណ៍សម្លាប់ សុន សេន និងក្រោយមកទៀតចាប់ ប៉ុល ពត កាត់ទោសអីមីងមានដឹងទេ?

គឿន: អត់ដឹងទេ ឮគេថា ។

វណ្ណៈ ឮគេថា មីងមិនដែលបានទៅចូលរួមប្រជុំអីទេ?

គឿន: ទេ ។

វណ្ណៈ ហើយខាងនេះតា០៥ឬ០៦នៅនេះ?

គឿន: ០៥ ។

វណ្ណៈ ចឹងតា០៥តាសារឿន?

គឿន: ចាស ។

វណ្ណៈ ចឹងក្រោយមកទៀតតាសារឿន គេចាប់អីហ្នឹងមីងមានបានដឹងដែរ?

គឿន: អត់ដឹង ។

វណ្ណៈ ចឹងក្រោយមកទៀតមានសមាហរណ៍កម្មកើតឡើងនៅសម័យហ្នឹង មានចុះចូលជាមួយរដ្ឋាភិបាលអីហ្នឹងមីងមានដឹងថា ពីណាជាអ្នកដឹកនាំចូលអី អ្នកដឹកនាំចូលជាមួយរដ្ឋាភិបាលបំបែកខ្លួនចេញពីតាម៉ុក?

គឿន: ដឹងតើ ។

វណ្ណៈ មានពីណាគេខ្លះ?

គឿន: តាជុំ នេះ ។

វណ្ណៈ មានតាជុំ មានពីណាទៀត?

គឿន: ខ្ញុំស្គាល់ប៉ុណ្ណោះឯង តាលាង តាអី ។

វណ្ណៈ	ចឹងមីងពេលដែលយើងបានចូលជាមួយរដ្ឋាភិបាលអីចឹង យើងប្រៀបធៀបការដែលយើងមានសង្គ្រាម តើមួយណាយើងអាចរស់នៅស្រួលជាង យើងប្រៀបធៀបរាល់ថ្ងៃជាមួយតាម៉ុក គ្រប់គ្រង?

គឿនៈ	សម័យនេះឯង សម័យ ហ៊ុន សែន នេះឯងស្រួលជាង ។

វណ្ណៈ	សម័យនេះស្រួលជាង?

គឿនៈ	ចាស ។

វណ្ណៈ	យើងរកបានប៉ុន្មានយើងហូបប៉ុណ្ណឹង?

គឿនៈ	ចាស!រកបានប៉ុន្មានហូបប៉ុណ្ណឹង ។

វណ្ណៈ	កូនចៅបានរៀនសូត្រ?

គឿនៈ	ចាស!កូនចៅបានរៀនសូត្រ សប្បាយមួយសេរី ។

វណ្ណៈ	ចឹងមីងរឿងរ៉ាវដែលមីងធ្លាប់ឆ្លងកាត់កន្លងមក មីងមានដែលនិយាយប្រាប់កូនចៅឲ្យបានដឹងដែលអត់?

គឿនៈ	ប្រាប់ ។

វណ្ណៈ	ប្រាប់ថា យ៉ាងម៉េចខ្លះ?

គឿនៈ	ប្រាប់ថា ប្រវត្តិម៉ែអី ពិបាក នៅតែក្នុងព្រៃរត់លូន ។

វណ្ណៈ	ចឹងពេលនិយាយរឿងប្រាប់ចឹង កូនចៅមានជឿមីងដែរ?

គឿនៈ	ជឿ ធ្វើម៉េចកុំឲ្យមានសង្គ្រាមទៀត កូនអើយខំ ស្រុកយើងឯករាជ្យហើយខំរៀនសូត្រ ។

វណ្ណៈ	បាទ ។

គឿនៈ	បើមិនបានការងារធ្វើក៏បានចំណេះដែលកូន បើបានការងារធ្វើបានទៅ បើមិនបានធ្វើម៉េចឲ្យកូនរៀនឲ្យចេះ ។

វណ្ណៈ	ចឹងមីងដូចជាសៀវភៅកម្ពុជាប្រជាធិបតេយ្យបានសរសេរពីឆ្នាំ១៩៧៥ដល់៧៩ សរសេររឿងរ៉ាវដូចមីងបានរៀបរាប់ចឹង បើដាក់ក្នុងកម្មវិធីសិក្សាឲ្យក្មេងៗរៀនអី មីងគិតថា មានសារសំខាន់មានផលប្រយោជន៍អីដែរ សៀវភៅដូចជាប្រវត្តិសាស្ត្រចឹង ឲ្យក្មេងរៀនតើធ្វើចឹងមីងគិតថាល្អដែលអត់?

គឿនៈ	ល្អ ។

វណ្ណៈ	យ៉ាងម៉េចបានជាមីងយល់ថាល្អ?

គឿនៈ	ឲ្យរៀនប្រវត្តិសាស្ត្រសៀវភៅតាម៉ុក ឬមួយយ៉ាងណា ។

វណ្ណៈ:	ប្រវត្តិដូចមីងបាននិយាយចឹង បើពួកខ្ញុំសរសេរហើយដាក់បញ្ចូលក្នុងកម្មវិធីសិក្សាអឲ្យក្មេងៗបានរៀនសូត្រឲ្យដឹងឬថាស្រុកយើងមានប្រវត្តិមួយចេះៗ មីងគិតថាល្អដែលអត់បើយើងធ្វើចឹង?

គឿនៈ	ល្អ ។

វណ្ណៈ:	ចឹងមីងគិតថា កូនចៅមីងមានចំណេះដឹង ខ្ពស់ខ្ពស់អាចថាជួយប្រទេសជាតិឲ្យមានការរីកចំរើននិងជួយខ្លួនឯងឲ្យបានល្អដែលអត់?

គឿនៈ	ឲ្យល្អខ្លួនឯងក៏ល្អឲ្យកូនក៏ល្អឲ្យជួយដល់ឪពុកម្ដាយក៏ល្អ ។

វណ្ណៈ:	ចឹងកូនមីងមានបានរៀនសូត្របានច្រើនទេ?

គឿនៈ	រៀនសូត្រមិនបានច្រើនទេ អាមួយពៅនោះរៀនបានត្រឹមថ្នាក់ទី១០ នៅឡើយ ។

វណ្ណៈ:	ចឹងកូនមុនៗ ?

គឿនៈ	មុនៗថ្នាក់ទី៧អាមួយនោះ វាយកប្រពន្ធទៅវាឈប់រៀនទៅ ។

វណ្ណៈ:	ចឹងដោយសារអីបានរៀនបានតិចតួច ដោយសារសាលាឆ្ងាយ?

គឿនៈ	ចាស!ដោយសារសាលាឆ្ងាយផងគ្រូមិនសូវជិតដល់ទេ គ្រូថាប្រាក់ខែតិច គាត់ថាចឹង ។

វណ្ណៈ:	ចឹងមីងជីវភាពមីងរាល់ថ្ងៃហ្នឹងជួបការលំបាកដែលអត់រាល់ថ្ងៃហ្នឹងអត់អីទេឬក៏យ៉ាងម៉េច?

គឿនៈ	ទេ យើងថាពិបាកក៏មិនដឹងថា យ៉ាងណាទេ ថាស្រណុកក៏មិនថាយ៉ាងណាទេ មធ្យម ។

វណ្ណៈ:	ចឹងកាលជំនាន់បីឆ្នាំមានជីវភាពយ៉ាងម៉េច?

គឿនៈ	ពិបាកណាស់ ។

វណ្ណៈ:	ចឹងជំនាន់មីងនៅជាមួយឪពុកម្ដាយជំនាន់លន់ នល់?

គឿនៈ	កាលហ្នឹងក៏ពិបាក រាល់ថ្ងៃឪពុកខ្ញុំមានស្រែចម្ការក៏ពិបាកដែរ ។

វណ្ណៈ:	តែពិបាកជាងគេកាលសម័យបីឆ្នាំ?

គឿនៈ	ចាស!ពិបាកជាងគេសម័យបីឆ្នាំម្យ៉ាងខ្លាចគេយកទៅសម្លាប់ ម្យ៉ាងហូបបាយមិនឆ្អែត ។

វណ្ណៈ:	ចឹងមកដល់សព្វថ្ងៃហ្នឹងព្រះពុទ្ធសាសនាវត្តអារាមអីមានទេ នៅក្នុងភូមិហ្នឹង?

គឿនៈ	វត្តមានតើ ។

វណ្ណៈ:	ចឹងមីងកាន់សាសនាអីដែរ?

គឿនៈ	ខ្ញុំធម្មតាមានកាន់អីទេ ។

វណ្ណៈ:	កាន់សាសនាព្រះពុទ្ធហ្នឹងមិនមែន?

គឿនៈ	អត់ទេ ដឹងសាសនាអីយេស៊ូយាយអីមិនដឹងទេ ព្រះពុទ្ធឯង ។

វណ្ណៈ:	មីងមានទៅវត្តទេ?

គឿន: ចាស! ទៅវត្ត ។
វណ្ណៈ: ចឹងបើទៅវត្តសាសនាព្រះពុទ្ធហើយ?
គឿន: ចាស ។
វណ្ណៈ: ចឹងមីងគិតថា យើងកាន់បាយសម្លទៅវត្តរាល់ភ្ជុំបិណ្ឌ ពេលថ្ងៃសិលអីហ្នឹង មីងទៅវត្តហ្នឹង មីងគិតថាមានផលប្រយោជន៍អីឬមីងគិតថា សាសនាព្រះពុទ្ធហ្នឹងនាំយើងឲ្យដើរផ្លូវល្អឬផ្លូវអាក្រក់ បើតាមមីងយល់?
គឿន: ចាស! សាសនាព្រះពុទ្ធនាំទៅផ្លូវល្អណា ។
វណ្ណៈ: ចឹងកាលសម័យខ្មែរក្រហមមានវត្តមានអីទេ?
គឿន: អត់មានទេ ។
វណ្ណៈ: ចឹងយើងអត់មានបានគោរពព្រះពុទ្ធសាសនាបានទេ?
គឿន: អត់មានទេ ។
វណ្ណៈ: ចឹងកាលសម័យពីដើមមានទេ?
គឿន: សម័យពីដើមមាន ។
វណ្ណៈ: ចឹងបើយើងនិយាយពីរឿងទំលាមទំលាប់ប្រពៃណីវិញ បើយើងចង់និយាយពីប្រពៃណីវិញ ដូចថាសម័យហ្នឹងក្មេងស្លៀកពាក់ សមរម្យដូចពីដើមដែលឬមួយខុសពីដើមមីង?
គឿន: ប្រពៃណីយ៉ាងម៉េច ។
វណ្ណៈ: និយាយពីការស្លៀកពាក់ ការគោរពចាសទុំអីពីដើម ពីដើមយ៉ាងម៉េចក្មេងកាលហ្នឹង?
គឿន: ទេ ពីដើមក្មេងៗសិស្សសាលាដូចខ្ញុំ ពាក់អាវសសំពត់ខៀវ ។
វណ្ណៈ: ឃើញចាស់ទុំគោរពយ៉ាងម៉េច?
គឿន: គោរពឃើញលោកឈរនៅចាំ ចាំលោកដើរផុតសិន បានដើរ ។
វណ្ណៈ: ចឹងមកដល់សម័យខ្មែរក្រហមយើងបានស្លៀកពាក់ស្អាតបាត មានហូរប្រមូងអីដែលមីង?
គឿន: អត់មានទេ ។
វណ្ណៈ: ចឹងសម័យឥឡូវ?
គឿន: មានទាំងអស់ ។
វណ្ណៈ: ចឹងមកដល់សព្វថ្ងៃហ្នឹងបើនិយាយពីអ្នកជិតខាងវិញមីង តើការរាប់អានគ្នាយ៉ាងម៉េចដែរ?
គឿន: រាប់អានធម្មតា ។
វណ្ណៈ: ចឹងកាលសម័យតាម៉ុក គ្រប់គ្រងមានការរាប់អានគ្នាយ៉ាងម៉េចដែរ?
គឿន: រាប់អានធម្មតាអ្នកជិតខាង ។

វណ្ណៈ៖ ចឹងអត់មានខុសគ្នាទេ  សម័យមួយចាយលុយសម័យមិនចាយលុយ  ចឹងការរាប់អានមានការខុសគ្នាខ្លះដែរ?

គឿនៈ ខុសគ្នាតើ ។

វណ្ណៈ៖ ខុសយ៉ាងម៉េច?

គឿនៈ ដូចថាសម័យចាយលុយខ្លះគ្នាអត់គ្នាក្រ  មិនចង់ដូចថាយើងគ្រាន់បន្តិចមិនសូវទេ  បើថាសម័យតាម៉ុក ចេះតែរាប់គ្នាទៅវាអត់ទាំងអស់គ្នា អត់មានចាយលុយ ។

វណ្ណៈ៖ ចឹងមានន័យថាសម័យនោះយើងបានអីហូបចែកគ្នាហូប?

គឿនៈ ចាស ។

វណ្ណៈ៖ ចឹងសម័យនេះយើងធ្វើអីបានយើងត្រូវការលក់យើងចែកគ្នាបានតិចតួចដែរ?

គឿនៈ ចាស! យើងត្រូវការលក់ ភាគច្រើនគឺលក់តែម្ដង ។

វណ្ណៈ៖ ចឹងកាលសម័យលន់ នល់ សម័យសង្គមរាស្ត្រនិយមអី ការរាប់អានជាមួយអ្នកជិតខាងយ៉ាងម៉េចដែលពេលនោះ?

គឿនៈ សម័យមុននោះដូចថាមិនសូវប៉ុន្មានទេ ខ្ញុំនៅតូចដែរ ។

វណ្ណៈ៖ ចឹងសម័យខ្មែរក្រហមការរាប់អានគ្នាត្រូវបានកាត់ផ្ដាច់ឬមួយយើងរាប់អានគ្នាបានល្អដែរ?

គឿនៈ ចាស!រាប់អានបានល្អ ។

វណ្ណៈ៖ ចឹងយើងរាប់អានទៅតាមអង្គភាព?

គឿនៈ ចាស!តាមអង្គភាព ។

វណ្ណៈ៖ ចឹងឥឡូវមីងបើយើងចង់ដាំដុះអីចឹង  តើមីងមានការពិភាក្សាជាមួយទេឬកូនចៅថាឆ្នាំនេះយើងត្រូវធ្វើអីឆ្នាំនោះត្រូវធ្វើអី  បែបហ្នឹងមានដែលពិភាក្សាទេ?

គឿនៈ មានពិភាក្សាតើ ។

វណ្ណៈ៖ ចឹងពិភាក្សាច្រើនមាននៅពេលណាដែរ  ពេលទំនេរឬយ៉ាងម៉េច?

គឿនៈ ពិភាក្សាពេលទំនេរ  ពេលអង្គុយលេងមើលទូរទស្សន៍ចេះទៅ ។

វណ្ណៈ៖ ចឹងនៅក្នុងភូមិឃុំនេះ  ភាគច្រើនប្រជាជនដាំដំណាំអីច្រើនជាងគេ?

គឿនៈ នៅកន្លែងនេះគេច្រើនដាំដំឡូង  ដំឡូងមី  ដាំស្រូវ  សណ្ដែកសៀង ។

វណ្ណៈ៖ មីងមានដីប៉ុន្មានហិចតាដែរ?

គឿនៈ ខ្ញុំមានតិចទេ  មានបួនទៅប្រាំហាត់ ។

វណ្ណៈ៖ ចឹងផលដំណាំទាំងអស់ហ្នឹងពេលធ្វើបានស្រួលលក់ចេញដែលឬមួយអត់ទេ?

គឿនៈ ស្រួលដែលតើ ឡានមកដល់ផ្ទះ ។

វណ្ណៈ: ចឹងតម្លៃអីយ៉ាងម៉េចដែរ?

គឿនៈ តម្លៃមិនចេះថាទេ ស្រូវគេឲ្យតែ៨០០រៀល ។

វណ្ណៈ: ថោកឬមួយថ្ងៃ៨០០ហ្នឹង?

គឿនៈ ថោក ។

វណ្ណៈ: ចឹងអត់សមហ្នឹងកម្លាំងយើងធ្វើទេ?

គឿនៈ អត់សម ។

វណ្ណៈ: ចឹងដីធ្លីទាំងអស់ហ្នឹង មានជួបបញ្ហាជាមួយក្រុមហ៊ុនឬក៏?

គឿនៈ ជួប ។

វណ្ណៈ: ចឹងជួបដែរ?

គឿនៈ ចាស ។

វណ្ណៈ: ចឹងឥឡូវដោះស្រាយយ៉ាងម៉េចហើយ?

គឿនៈ អត់មានដោះស្រាយអីទេ គេអត់មានដោះឲ្យ ។

វណ្ណៈ: ចឹងអត់មានខាងនិសិត្សចុះមកទេ?

គឿនៈ មានមកតើ ពួកខ្ញុំមិនទាន់ដល់ ខាងនិសិត្សនោះបាត់ស្ងាត់ឈឹងទៅ តាំងពីបោះឆ្នោតហើយ បាត់រហូត ។

វណ្ណៈ: ចឹងចាំមើលបន្តិចទៀតប្រហែលជាមានក្រុមនិសិត្សចុះមកទៀត តែរាល់ថ្ងៃវានៅមានបញ្ហាខ្លះ ព្រោះរដ្ឋាភិបាលហ្នឹងមិនទាន់បានដើរស្រួល ទើបបោះឆ្នោតហើយចឹង ចឹងបើសិនជាមានប៉ះពាល់ដីធ្លីឬកូនចៅមានបញ្ហាឈ្លោះទាស់ទែងគ្នា តើមីងអាចពឹងពាក់ទៅលើផ្នែកច្បាប់ មីងគិតថា ច្បាប់យើងសព្វថ្ងៃហ្នឹងអាចជួយដោះស្រាយបានអត់?

គឿនៈ ទុកចិត្តបាន ។

វណ្ណៈ: ចឹងកាលសម័យខ្មែរក្រហមវិញមានច្បាប់ទំលាប់មានទេ?

គឿនៈ អត់សូវមានប៉ុន្មានទេ ។

វណ្ណៈ: ចឹងបើមានមនុស្សធ្វើខុសអត់មានយកទៅកាត់ទោសទេ យកទៅវាយចោលតែម្ដង?

គឿនៈ យកទៅវាយចោល ។

វណ្ណៈ: ចឹងអត់មានកាត់ទោសថាអ្នកនេះខុសអីៗទេ យកទៅវាយចោលតែម្ដង?

គឿនៈ ចាស! តែអារឿងគេយកទៅវាយចោលនោះខ្ញុំមិនសូវដឹងទេ ស្រាប់តែគេថាស្លាប់បាត់ ហើយមិនដឹងថាគេកាត់ទោសអីយ៉ាងម៉េច ។

វណ្ណៈ: ចឹងនៅក្នុងសម័យខ្មែរក្រហមមីងមានដឹងថាមានតុលាការកាត់ទោសអីនិងមានវិទ្យុស្ដាប់ទេ?

គឿន៖ មានវិទ្យុ តែការកាត់ទោសមិនសូវដឹងដែរ ។

វណ្ណៈ៖ ចឹងមីងនៅក្នុងភូមិឃុំហ្នឹង មានកូនចៅចាកចេញពីផ្ទះសំបែងទៅធ្វើការនៅស្រុកថៃឬណាទេមីង?

គឿន៖ អត់មានទេ ។

វណ្ណៈ៖ ចឹងឬថាខ្លះឡើងនៅកាបឈើក្រញូងស្រុកថៃ គេបាញ់ស្លាប់អីនោះមានទេ?

គឿន៖ មាននៅខាងកើតគេអ្នកទៅកាប់ក្រញូង គ្នាក្រពេក ។

វណ្ណៈ៖ ចឹងមូលហេតុមកពីក្រពេក?

គឿន៖ ចាស ។

វណ្ណៈ៖ ចឹងមានខាងរដ្ឋអំណាចបានហាមឃាត់ដែរ?

គឿន៖ ចាស! តែចេះតែទៅ ។

វណ្ណៈ៖ ចឹងឈើនៅស្រុកយើងហ្នឹងចាប់ផ្តើមអស់នៅឆ្នាំណា មីងមានដឹងទេ?

គឿន៖ អត់ដឹងទេ ។

វណ្ណៈ៖ ចឹងកាលមីងមកដល់ដំបូងនៅមាន?

គឿន៖ ចាស ។

វណ្ណៈ៖ ចឹងមីងខ្ញុំដូចជាអស់អីសួរមីងហើយខ្ញុំអរគុណមីងច្រើន ។

គឿន៖ ចាស ។

សុវណ្ណៈ ខ្ញុំចង់ថែមបន្តិច មីងខ្ញុំចឹងដឹងយោបល់របស់មីងផ្ទាល់ មីងឆ្លងកាត់ពីមុនមកឆ្លងកាត់របបខ្មែរក្រហមរបបសម័យតស៊ូ រត់លូនគ្រាប់ចុះឡើងចឹង អារម្មណ៍សម្រាប់មីងពេលមានសង្គ្រាមហ្នឹងយ៉ាងម៉េចដែលសម្រាប់មីង?

គឿន៖ ខ្ញុំយល់ថាឥឡូវនេះវាយស្រួល អត់មានសង្គ្រាមអី អ្នកដឹកនាំល្អបានអត់មានសង្គ្រាម ។

សុវណ្ណៈ ចឹងមីងគិតថា សង្គ្រាមមានផ្តល់ផលប្រយោជន៍ឲ្យប្រជាជនទេ?

គឿន៖ អត់មានទេ ។

សុវណ្ណៈ មូលហេតុអីមីង ចង់និយាយថា សង្គ្រាមមានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជនឬមួយមិនផ្តល់ទេមីង?

គឿន៖ អត់មានផ្តល់ឲ្យទេ ។

សុវណ្ណៈ មូលហេតុអី?

គឿន៖ មូលហេតុយើងមិនបានធ្វើអី រត់ចុះរត់ឡើង ចេះតែខ្លាចបើមានសង្គ្រាម ។

សុវណ្ណៈ ចឹងសម្រាប់ចង់ឲ្យមានសង្គ្រាមវិញមកវិញឬមួយយ៉ាងម៉េច?

គឿនៈ អត់មានទេ ឲ្យមករកអី ។

សុវណ្ណៈ ចឹងមីងពេញចិត្តការរស់នៅក្នុងពេលបច្ចុប្បន្ននេះទេ?

គឿនៈ ពេញចិត្ត ។

សុវណ្ណៈ មូលហេតុអីបានជាមីងពេញចិត្ត?

គឿនៈ មូលហេតុល្អដឹកនាំល្អ ដឹងខុសដឹងត្រូវ ប្រជារាស្ត្រណាខុសគេដឹងថាខុស ត្រូវដឹងថាត្រូវមិនយកដូចសម័យខ្មែរក្រហមទេ ។

សុវណ្ណៈ សម័យខ្មែរក្រហមយ៉ាងម៉េច?

គឿនៈ សម័យខ្មែរក្រហមមិនដឹងថាខុសត្រូវទេ យកគ្នាទៅវាយចោល ហូបបាយក៏មិនឆ្អែត ចឹងអីមិនបានហូបខ្លួនឯង ចិញ្ចឹមខ្លួនឯងក៏មិនហ៊ានហូប ។

សុវណ្ណៈ ចឹងកាលរបបបីឆ្នាំប្រាំបីខែម្ភៃថ្ងៃ មីងមិនដែលបានគោរពសាសនាទៅវត្តអី ហើយពេលសព្វថ្ងៃនេះមីងមានសិទ្ធទៅវត្តទៅវ៉ា ចង់ធ្វើអីក៏បាន ចឹងមីងគិតថា ការទៅវត្តនៅពេលបច្ចុប្បន្នមីងគិតថា ចង់ទៅក៏បានទៅក៏បានមីងមានដែលគិតចឹងទេ?

គឿនៈ អត់ទេ ចង់តែទៅ មានពេលខ្លះយើងចាលលុយហើយ មិនបាច់ទៅទេ ចាំទៅក្រោយទៀតចឹងទៅ ។

សុវណ្ណៈ ចឹងមានមូលហេតុអីមីងត្រូវតែទៅ ព្រោះនិយាយឲ្យចំទៅមីងខានគោរពសាសនាតាំងពីយូរមកហើយតាំងពីឆ្នាំ១៩៧៥រហូតមកដល់យើងផ្តាច់ខ្លួនឆ្នាំ១៩៩៨ ចូលសមាហរណ៍កម្មចឹងបានយើងទៅវត្តទៅវ៉ា ចឹងវាយូរមកហើយបើសិនយើងគិតមើលរយៈពេលហ្នឹង ពេលឥឡូវមីងទៅវិញ មីងគិតថា គួរតែទៅឬមិនទៅ ទៅក៏បានមិនទៅក៏បាន មីងមានដែលគិតចឹងទេ?

គឿនៈ មានគិតដែរ ។

សុវណ្ណៈ គិតថាយ៉ាងម៉េច?

គឿនៈ ទៅច្រើនពេក ក៏ផ្អាកខ្លះដូចថាមិញហ្នឹង ទៅញឹកពេកក៏ផ្អាកខ្លះ ។

សុវណ្ណៈ ចឹងមីងគិតថា មិនចង់គោរពប្រត្តិបត្តិតែម្តងមីងមានដែលគិតចឹងទេ?

គឿនៈ អត់ដែលទេ ចង់គោរព ។

សុវណ្ណៈ មូលហេតុអីមីង?

គឿនៈ ចង់គោរពរហូត ។

សុវណ្ណៈ មានមូលហេតុអីធ្វើឲ្យមីងចង់គោរពរហូត?

គឿនៈ ចង់ធ្វើបុណ្យតែម្ដង ចង់ធ្វើបុណ្យទោះបីបានមិនបានក៏ចង់ធ្វើ អារម្មណ៍នៅចង់ធ្វើបុណ្យ ចង់ទៅវត្ត តែពេលណាផ្អាកមិនបានទៅក៏អារម្មណ៍ថា អឺ!មិនបានទៅទេ ចាំថ្ងៃសិលក្រោយចាំទៅម្ដង វាពិបាកខ្លួនឯង ម្យ៉ាងសុខភាព ម្យ៉ាងអត់មានពីណាកូនស្ទុះតែប្រុស ។

សុវណ្ណៈ ចឹងមីងមានដែលនិយាយប្រវត្តិមីងនិយាយប្រាប់ពួកខ្ញុំ និងមាននិយាយប្រាប់ក្មេងៗពីមុនមកទេ?

គឿនៈ មានប្រាប់ ។

សុវណ្ណៈ ចឹងខ្ញុំដូចជាគ្មានអីដែលមីងខ្ញុំអរគុណច្រើន ។

គឿនៈ ចាស ។

**ចប់**